## សូមស្វាគមន៍

# ក្រុមហ៊ុនមេធាវី Marcotte សូមស្វាគមន៍ - Lowell, Massachusetts

ក្រុមហ៊ុនមេធាវី Marcotte នៅ Lowell, Massachusetts ត្រូវបានបង្កើតឡើងដោយមេធាវីមួយក្រុម និងបុគ្គលិកច្បាប់ដែលមានការប្តេជ្ញាចិត្តចំពោះការផ្តល់សេវាដែលមានប្រសិទ្ធភាពក្នុងតម្លៃសមរម្យ ។ ការខិតខំព្យាយាមដើម្បីរកដំណោះស្រាយផ្នែកច្បាប់របស់យើងខ្ញុំកំណត់លក្ខណៈដោយសុភវិនិច្ឆ័យ ។ យើងខ្ញុំមានបទពិសោធន៍ផ្នែកច្បាប់រួមគ្នាជាង 150 ឆ្នាំ ហើយមានការប្តេជ្ញាចិត្តចំពោះការបម្រើសហគមន៍ Massachusetts ភាគខាងជើង ។ កេរ្តិ៍ឈ្មោះនៃឧត្តមភាពរបស់យើងខ្ញុំកើតចេញពីសមត្ថភាពរបស់យើងខ្ញុំក្នុងការកំណត់ចំណុចស្នូលនៃបញ្ហាផ្លូវច្បាប់របស់កូនក្តីយើងខ្ញុំ ហើយផ្តល់ការប្រឹក្សា និងតំណាងដោយអាណត្តិគួរឱ្យពេញចិត្ត ។

នៅក្រុមហ៊ុនមេធាវី Marcotte យើងខ្ញុំយល់ពីតម្រូវការផ្សេងៗគ្នារបស់សហគមន៍ ។ តម្លៃនៃការតំណាងដោយអាណត្តិ ត្រូវអន់ថយ នៅពេលដែលទំនាក់ទំនងរវាងបណ្តាភាគីមានភាពលំបាក ឬថែមទាំងមិនអាចទៅរួច ។ ក្រុមរបស់យើងខ្ញុំមានសមាជិកពេញម៉ោង ដែលស្ទាត់ជំនាញភាសាអេស្ប៉ាញ និងភាសាខ្មែរ ដែលចង់ជួយសម្រួលដល់រាល់លក្ខណៈនៃដំណើរការបណ្តឹងវិវាទ ។ ជំនាញរបស់ពួកគេជួយដល់អ្នកដទៃយ៉ាងច្រើន ដោយខិតខំប្រឹងប្រែងដោះស្រាយបញ្ហាឱ្យបានកាន់តែឆាប់តាមដែលអាចធ្វើបាន ។

ទោះបីជាលោកអ្នកមានការព្រួយបារម្ភអំពីឧបសគ្គផ្នែកភាសា ដែលអាចរារាំងដល់លទ្ធភាពរបស់លោកអ្នក ក្នុងការទទួលបានអ្នកតំណាងដោយអាណត្តិក៏ដោយ សូមទាក់ទងការិយាល័យរបស់យើងខ្ញុំថ្ងៃនេះ ដើម្បីធ្វើការណាត់ជួបប្រឹក្សាជាលើកដំបូងដោយឥតគិតថ្លៃ ។

## ប្រសិទ្ធភាព

មេធាវី និងអ្នកជំនួយមេធាវីរបស់យើងខ្ញុំធ្វើការជាក្រុមយ៉ាងស្អិតរមួត ផ្តោតអារម្មណ៍លើការផ្តល់សេវាដែលមានលទ្ធផលខ្ពស់ដល់កូនក្តី ។ ដោយសារមានសេចក្តីអន្តរាយដល់បុគ្គលជាច្រើន ដូចជាគ្រោះថ្នាក់នៅការដ្ឋាន ចូលរួមក្នុងការដាក់ពាក្យបណ្តឹងតវ៉ា ឱ្យបានទាន់ពេលវេលា បុគ្គលិករបស់យើងខ្ញុំធ្វើការដោយខ្លាចនឿយហត់ និងស្វះស្វែងរកគ្រប់មធ្យោបាយដែលចាំបាច់សំរាប់ការធានាដល់កូនក្តីរបស់យើងខ្ញុំនូវដំណោះស្រាយភ្លាមៗដែលពួកគាត់គួរនឹងទទួលបាន ។

## គួរឱ្យពេញចិត្ត

នៅក្រុមហ៊ុនមេធាវី Marcotte យោបល់ និងដំបូន្មានរបស់យើងខ្ញុំផ្អែកលើចំណេះដឹង ដែលទទួលបានពីបទពិសោធន៍ច្បាប់រួមគ្នាជាច្រើន រយៈពេល 150 ឆ្នាំ ។ ជាជាងការផ្តល់ក្តីរំពឹង និងការទស្សន៍ទាយដែលមិនប្រាកដប្រជា យើងខ្ញុំផ្តល់ការពិត ។ លោកអ្នក

អាចទុកចិត្តបានលើមេធាវីរបស់យើងខ្ញុំ ដែលតែងតែផ្តល់ដំបូន្មានត្រឹមត្រូវ សមហេតុសមផល នៅក្នុងបញ្ហាដែលពាក់ព័ន្ធនឹងច្បាប់ធានារ៉ាប់រង បណ្តឹងវិវាទទូទៅ ច្បាប់គ្រួសារ និងផែនការអចលនទ្រព្យ ។

**ប្រសិទ្ធភាព**

កេរ្តិ៍ឈ្មោះជាច្រើនរបស់យើងខ្ញុំនៅក្នុងសហគមន៍នេះ ផ្អែកលើកំណត់ហេតុនៃភាពជោគជ័យរបស់យើងខ្ញុំ ។ តាមរយៈការស្តាប់កង្វល់របស់កូនក្តីយើងខ្ញុំ ដោយស្វែងរកគ្រប់ជម្រើស និងផ្តល់ជម្រើសដែលប្រកបដោយប្រឌិតញាណ យើងខ្ញុំអាចសម្រេចបាននូវលទ្ធផលដែលអាចកើតឡើងល្អបំផុតជូនចំពោះកូនក្តីជាច្រើនរបស់យើងខ្ញុំ ។ មិនថារឿងក្តីពាក់ព័ន្ធនឹងបំណុលអចលនទ្រព្យ គ្រោះថ្នាក់ចរាចរណ៍ ឬរឿងក្តីរំលោភបទព្រហ្មទណ្ឌធ្ងន់ធ្ងរ ដូចជាបើកបរនៅពេលស្រវឹង ឬបទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀនក៏ដោយ ក៏មេធាវីកាត់ក្តីរបស់យើងខ្ញុំផ្តល់ការតស៊ូមតិដែលមានតម្លៃនៅតុលាការដែរ ។

**សេចក្តីអន្តរាយដល់បុគ្គល**

**សំណងបុគ្គលិក**

**ពិការភាពដោយសន្តិសុខសង្គម**

**គ្រោះថ្នាក់ចរាចរណ៍**

**គ្រោះថ្នាក់នៅការដ្ឋាន**

**បំណុលអចលទ្រព្យ**

**ច្បាប់ធានារ៉ាប់រង**

**ការរំលោភបទព្រហ្មទណ្ឌ**

**បើកបរនៅពេលស្រវឹង & ប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍**

**បទព្រហ្មទណ្ឌផ្លូវភេទ & ថ្នាំញៀន**

**ច្បាប់គ្រួសារ & ផែនការអចលនទ្រព្យ**

**បណ្តឹងវិវាទទូទៅ**